# ផលិតកម្មដំណាំត្របែកសំរាប់កសិករ



រៀបចំដោយមានការចូលរួមពីអង្គការ សន្តិសេនា សមាគមមនុស្សចាស់ ពោធិធំ អង្គការចិត្តធម៌ និង អង្គការ ស៊ី អារ អែស កម្មវិធីកសិកម្ម

ដក់ស្រង់ពីឯកសារឈើហូបផ្លែរបស់អង្គការ ប៉ាដិក ស៊ីដសេ និង សាលាជាតិកសិកម្មព្រែកលៀប

# មាតិការ

ទំព័រ

១- សេចក្តីផ្តើម..........................................០១

២-ការជ្រើសរើសពូជ..........................................០២

៣- ការបណ្តុះកូន..........................................០២

ក. ជ្រើសរើសទីតាំងថ្នាល..........................................០២

ខ. ការរៀបចំថ្នាល..........................................០២

គ. ការបណ្តុះកូនត្របែក..........................................០៣

ឃ. ការផ្សាំក្នុងថង់..........................................០៤

៤- ការដាំដុះ..........................................០៥

ក. ការជ្រើសរើសទីកន្លែងដាំដុះ..........................................០៥

ខ. របៀបជីករណ្តៅ..........................................០៥

គ. ការដាក់ជីក្នុងរណ្តៅ..........................................០៦

ឃ. ការដាំកូនត្របែក..........................................០៧

៥- ការថែទាំ..........................................០៧

ក. ការដាក់ជីបំប៉ន..........................................០៧

ខ. ការស្រោចទឹក..........................................០៨

គ. ការតាក់តែងមែក..........................................០៨

ឃ. ការការពារជម្ងឺ និង សត្វល្អិតចង្រៃ..........................................១០

៦- ការប្រមូលផល..........................................១០

៧- ការបន្តពូជ..........................................១០

ក. ការបន្តពូជដោយគ្រាប់..........................................១០

ខ. ការបន្តដោយសាកមែក..........................................១០

## ១-សេចក្ដីផ្ដើម

ត្របែកគឺជារុក្ខជាតិមួយដែលកសិករភាគច្រើននិយមដាំ ព្រោះអាចដុះលូតលាស់បានលើដីស្ទើរតែគ្រប់ប្រភេទ។ វាមានប្រយោជន៏ច្រើនយ៉ាងដូចជា ហូបផ្លែស្រស់ជាបង្អែម ជ្រក់ ដើមធ្វើជាសំភារៈសង្ហារឹមផ្សេងៗ ជារបាំងខ្យល់ ជាម្លប់ និង ស្លឹកជាជី ។

## ២-ការជ្រើសរើសពូជ

ពូជត្របែកដែលអាចយកមកដាំបាននោះគឺ ពូជឆាប់ផ្លែ ធន់ជំងឺ ផ្លែធំ សាច់ក្រាស់ រស់ជាតិឆ្ងាញ់ មានប្រភពច្បាស់លាស់ និង តម្រូវការសំរាប់ទីផ្សារខ្ពស់ ។



## ៣-ការបណ្ដុះកូន

### ក. ជ្រើសរើសទីតាំងថ្នាល:

ទីតាំង និង ការរៀបចំថ្នាលជាកត្តាមួយដ៏សំខាន់សំរាប់ធ្វើអោយការដុះពន្លកនៃកូនដំណាំបានគង់វង់ក្នុងបរិមាណខ្ពស់ និង សុខភាពល្អនោះដូចជា:- ក្បែរប្រភពទឹកដីទួលមិនលិចទឹក មានពន្លឺគ្រប់គ្រាន់ និង ជាទីកន្លែងដែលមានសុវត្ថិភាព ។

### ខ. ការរៀបចំថ្នាល:

ត្រូវលើកដីថ្នាលអោយបានកំពស់ពីរតឹក ទទឹងមួយម៉ែត្រ និង បណ្ដោយអាស្រយ័ទៅតាមប្រវែងជាក់ស្ដែងដែលចង់បាន កាប់ដីអោយម៉ត់ ហាលរយៈពេលពីពីរ ទៅ បីសប្ដាហ៍ ដើម្បីសំលាប់បាក់តេរី ឬ សត្វល្អិតចង្រៃផ្សេងៗ និង ជ្រោយដីរួចជ្រើសយកស្មៅចេញ ។



គ.ការបណ្ដុះកូនត្របែកៈ

ត្រូវលាងគ្រាប់ត្របែកនិងទឹកអោយបានស្អាតរួចហាល និង កំដៅថ្ងៃ ពីពីរ ទៅ បីថ្ងៃ ពង្រាយគ្រាប់លើរងដែលបានរៀបចំជាស្រេចចំងាយប្រហែលកន្លះតឹក ពីគ្រាប់មួយ ទៅគ្រាប់មួយ លុបដីម៉ត់ពីលើគ្រាប់អោយបានជិតល្អ ក្របកំណាត់ចំបើងចិញ្ច្រាំខ្លីៗ ស្រោចទឹកអោយសើមជាប្រចាំ។



## ឃ. ការផ្សាំកូន :

កូនត្របែកត្រូវយកទៅផ្សាំក្នុងថង់បានលុះត្រាណាថង់ត្រូវច្រកដោយដីកំប៉ុស្តិ៍មួយភាគ អង្កាមមួយភាគ និង ដីខ្សាច់មួយភាគជាស្រេច ហើយស្រោចទឹកភ្លាមដើម្បីអោយឫស ចាប់ជាប់ ជាមួយដីថ្មីក្នុងថង់។



## ៤-ការដាំដុះ

### ក.ការជ្រើសរើសទីកន្លែងដាំដុះ :

ត្រូវដាំត្របែកនៅកន្លែងណាដែលមានសុវត្ថិភាព ដីខ្ពស់ដែលមិនលិចទឹក មានដីជាតិល្អ ហើយមានសំណើមល្មម និង ឆ្ងាយពីដើមឈើធំៗដែលមានស្រាប់យ៉ាងហោចណាស់ ១០ម៉ែត្រ មានប្រភពទឹកនៅក្បែរងាយស្រួលក្នុងការស្រោចស្រពនៅពេលជួបប្រទះការរាំងស្ងួត ។

### ខ.របៀបជីករណ្តៅ:

រណ្តៅដាំដែលទំហំសមល្មមគឺ ជំរៅប្រាំបីតឹក បណ្តោយប្រាំបីតឹក និង ទទឹងប្រាំបីតឹក (ប្រាំបីតឹកបួនជ្រុង) គំលាតពីរណ្តៅមួយទៅរណ្តៅមួយយ៉ាងហោចណាស់៦ម៉ែត្រ ហើយត្រូវធ្វើយ៉ាងណាកំណត់ជួរអោយប៉ះ និង ពន្លឺព្រះអាទិត្យស្មើគ្នា ។



គ.ការដាក់ជីក្នុងរណ្ដៅ:

ក្រោយពេលជីករណ្ដៅរួច មុនពេលដាំត្រូវប្រមូលសំរាមដែលបានពីរុក្ខជាតិ ផេះ លាមកសត្វ ឬ ជីកំប៉ុស្ដិ៍ដាក់ក្នុងរណ្ដៅអោយបានច្រើនជាការប្រសើរព្រោះវាជាជីធម្មជាតិដែលផ្ទុកទៅដោយអាហារធាតុចិញ្ចឹមច្រើនយ៉ាង ។



ឃ.ការដាំកូនត្របែកៈ

ត្រូវពិនិត្យ និង អនុវត្តអោយបានហ្មត់ចត់ដូចជា :- កូនត្របែកត្រូវមាន អាយុយ៉ាងតិចមួយខែត្រូវជៀរថង់ថ្នមៗនិងកាំបិតមុតជៀសវាងបែកដី ដាំនៅពេលរសៀល រួចស្រោចទឹកអោយបានសើមដើម្បីអោយដីថ្មី ចាស់ និង គល់កូនត្របែកចាប់ជាប់គ្នាហើយវាមានលទ្ធភាពស្រូបសំណើមបាន ។

## ៥.ការថែទាំ

### ក-ការដាក់ជីបំប៉នៈ

ជីបំប៉ន់ត្រូវដាក់ពីរដងក្នុងមួយឆ្នាំ គឺនៅរៀងរាល់ដើម និង ចុងរដូវវស្សា ជីករណ្តៅពទ្ធជុំវិញគល់ត្របែកដោយគិតចំងាយពីគល់ទៅទន្ទឹម និង ចុងមែកដែលបែកចេញទៅខាងវែងជាងគេជុំវិញដើមជំរៅកន្លះម៉ែត្រ ទំហំពីពីរ ទៅ បួនតឹក ដាក់ធម្មជាតិ និងជីគីមីសមាសដែលមានធាតុ អ៊ិន ប៉េ កា (ប៉ុន្តែមិនអាចដាក់តែជីគីមីសុទ្ធទេ) ។



ខ-ការស្រោចទឹកៈ

ស្រោចទឹកដើម្បីបង្កលក្ខណៈងាយស្រួលដល់រោមជញ្ជក់របស់ឬសស្រូបយកអាហារ ធាតុ ស្រោចទឹកបំប៉នអោយបានទៀងទាត់នៅពេលកូនត្របែកនៅតូច ស្រោចទឹកបន្ថែមពេលណាដែលយើងសង្កេតឃើញថាដំណាំត្របែកខ្វះជាតិទឹកនៅពេលវាពេញវ័យ ស្រោចទឹកបំប៉នអោយបានច្រើនជាប្រចាំនៅមុន និង ក្នុងពេលដំណាំត្របែកចេញផ្កា ។

គ-ការតាក់តែងមែកៈ

ការតាក់តែងមែកគឺត្រូវធ្វើឡើងរៀងរាល់បួនឆ្នាំម្តង ក្រោយពេលប្រមូលផលរួច ហើយមែកដែលត្រូវកាត់ចោលនោះមានដូចជា :- មែកចាស់ពេក( មិនផ្លែ) មែកមានចុងសំយ៉ុងចុះ មែកដុះចាក់ទៅក្នុង មែកមានជំងឺ មែកមានដុះរុក្ខជាតិបញ្ញើរក្អែក ។ ការធ្វើរបៀបនេះដើម្បីអោយសុខភាពមែកល្អ ទទួលពន្លឺបានគ្រប់គ្រាន់ និង ស្រូបយកខ្យល់បានល្អធ្វើអោយត្របែកផ្លែធំ ។

ម.ព.ឯ.ក AIDOC
Code:
Date:
Donated by:


មែកពីកំណើត


មែកបានតាក់តែង

## ឃ. ការការពារជម្ងឺ និង សត្វល្អិតចង្រៃ:

យើងមានវិធីច្រើនយ៉ាងដូចជា ដាក់កំបោរស សាចជូរខ្យេវ ស្ពាន់ធ័រ ជុំវិញគល់ ការពារសត្វកន្ធៀវ ប្រើថ្នាំគីមីពុលកសិកម្មម៉ាឡាចុងនៅពេលសត្វល្អិតបំផ្លាញផ្កា ឬ ក្តិប(រាល់ពេលដែលប្រើថ្នាំពុលគីមីត្រូវដាក់ផ្លាក់សញ្ញាសំគាល់ជៀសវាងមានគ្រោះថ្នាក់ដល់មនុស្ស និង សត្វ)មែកដែលមានជំងឺត្រូវកាប់រួចយកទៅកប់ ឬ ដុតចោល និង បំពក់ភ្លើងដើម្បីអោយផ្សែងហុយបណ្តេញសត្វល្អិត ។

## ៧-ការបន្តពូជ

មានវិធីច្រើនយ៉ាងសំរាប់បន្តពូជត្របែក ប៉ុន្តែមានវិធីតែពីរទេដែលសមស្របសំរាប់កសិករគឺមានដូចក្រោម ៖-

### ក.ការបន្តពូជដោយគ្រាប់:

ការបន្តពូជដោយគ្រាប់គឺជាវិធីមួយដែលមានលក្ខណៈល្អ និង ងាយស្រួលជាង គេ ការដាំដោយគ្រាប់គឺលូតលាស់បានល្អ មានប្រពន្ធ័ឫសមាំ ធនទ្រាំជំម្ងឺ មានអាយុកាល លូតលាស់វែងប៉ុន្តែមានការចុះតូចនៃទំហំផ្លែពីមួយជំនាន់ទៅមួយជំនាន់ចំពោះពូជមួយចំនួន។

### ខ.ការបន្តដោយសាកមែក:

ការដាំត្របែកដោយមែកសាកឆាប់អោយផលគឺក្នុងរយៈពេលពីប្រាំមួយទៅ មួយឆ្នាំក្រោយពេលដាំតែប៉ុណ្ណោះ ប៉ុន្តែវាមានអាយុខ្លីជាងការដាំដោយគ្រាប់ព្រោះការលូតលាស់នៃឫស និង ដើមពុំមានតុល្យភាពគ្នា ។ ការសាកមែកត្រូវធ្វើតាមរបៀបដូចជា ជ្រើរើសមែកណាដែលមានសុខភាពល្អ ប្រវែងប្រហែលមួយម៉ែត្រ លាក់សំបកក្រឡឹងជុំវិញមែកដែលមានប្រវែងស្មើ និង ទំហំនៃមែក បកសំបកចេញ កោសរំអិល រក្សាទុករយៈពេលប្រហែពី១៥ ទៅ ៣០នាទី ចងថង់ផ្លាស់ស្ទិកដែល~~ស្រុក~~ពេញដោយកំប៉ុស្តិ៍សើមជុំវិញមែកដែលកោសរួច ចងខ្សែរិតចំកណ្តាលអោយណែន ស្រោចទឹកអោយសើមជាប្រចាំ និង កាត់យកមែកដែលបានសាក

ច្រកក្នុងថង់ផ្សាំនៅពេលដែលយើងសង្កេតឃើញថាឫសដែលដុះមានពណ៌ត្នោត ។

